ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧ ០២/២៤.០០១.សរ.ត.ជក

ថ្ងៃព្រហស្បតិ៍ ១០ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំឥណទានឡើងវិញ

ក្នុងគោលបំណងជួយសម្រាលបន្ទុកចំណាយប្រចាំគ្រារបស់អតិថិជនក្នុងការបំពេញកាតព្វកិច្ចសងត្រឡប់ឥណទាន និងជំរុញកំណើនសេដ្ឋកិច្ចតាមរយៈការបង្កើនលំហូរសាច់ប្រាក់ ធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" រៀបចំឥណទានឡើងវិញជូនអតិថិជន ដោយត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

- គ្រឹះស្ថានអាចរៀបចំឥណទានឡើងវិញជូនអតិថិជនបានចំនួន ២ (ពីរ) ដង ដោយអាចរក្សាចំណាត់ថ្នាក់ដដែល និងមិនចាំបាច់ធ្វើសំវិធានធនបន្ថែម។
- គ្រឹះស្ថានអាចអនុវត្តការដំឡើងចំណាត់ថ្នាក់ឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះនេះ លើកដំបូងពីមួយកម្រិតទៅមួយកម្រិត បន្ទាប់ពីអតិថិជនបានបំពេញកាតព្វកិច្ចទូទាត់សងបន្តបន្ទាប់គ្នាក្នុងរយៈពេលយ៉ាងតិច ៣ (បី) ខែ ចំពោះឥណទានដែលមានការទូទាត់សងប្រាក់ដើម និង/ឬ ការប្រាក់ប្រចាំខែ។ បន្ទាប់មក គ្រឹះស្ថានអាចស្តារចំណាត់ថ្នាក់ឥណទានល្អជាងមុនពីមួយកម្រិតទៅមួយកម្រិតទៀត ដោយគោរពតាមគោលការណ៍ចំនួនថ្ងៃហួសកាលកំណត់សងនៃការទម្លាក់ចំណាត់ថ្នាក់ឥណទាន។ លើសពីនេះ ការដំឡើងចំណាត់ថ្នាក់ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

  ក. ចំពោះឥណទានមិនដំណើរការដែលមិនធ្លាប់ត្រូវបានរៀបចំឡើងវិញ (លើកលែងឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះកន្លងមក) ហើយបានស្នើសុំការរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះនេះ ការដំឡើងចំណាត់ថ្នាក់អាចធ្វើពីមួយកម្រិតទៅមួយកម្រិតរហូតដល់ចំណាត់ថ្នាក់ "ស្តង់ដា"

  ខ. ចំពោះឥណទានដំណើរការដែលធ្លាប់ត្រូវបានរៀបចំឡើងវិញមួយលើក (លើកលែងឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះកន្លងមក) ហើយក្លាយជាឥណទានមិនដំណើរការ និងបានស្នើសុំការរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះនេះ ការដំឡើងចំណាត់ថ្នាក់អាចធ្វើពីមួយកម្រិតទៅមួយកម្រិតរហូតដល់ចំណាត់ថ្នាក់ "ស្តង់ដា"



ប្រអប់សំបុត្រលេខ ២៥, អគារលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ . ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

គ. ចំពោះឥណទានមិនដំណើរការដែលធ្លាប់ត្រូវបានរៀបចំឡើងវិញ (លើកលែងឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះកន្លងមក) ហើយបានស្នើសុំការរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះនេះ ការដំឡើងចំណាត់ថ្នាក់មិនអាចខ្ពស់ជាង "ក្រោមស្តង់ដា" ទេ។

ការដំឡើងចំណាត់ថ្នាក់នេះ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីត្រីមាសទី៤ ឆ្នាំ២០២៤ តទៅ។ ទន្ទឹមនេះ ការដំឡើងចំណាត់ថ្នាក់នេះ ក៏ត្រូវបានអនុវត្តចំពោះឥណទានរៀបចំឡើងវិញចំពោះវិស័យទេសចរណ៍នៅខេត្តសៀមរាប ដែលបានកំណត់នៅក្នុងសារាចរណែនាំលេខ ធ៧.០២៣.០០១ សារាចរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ផងដែរ។

- គ្រឹះស្ថានមិនគួរប្រើប្រាស់តែព័ត៌មានឥណទានរៀបចំឡើងវិញក្នុងក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី ក្នុងអំឡុងពេលអនុគ្រោះនេះ ជាលក្ខខណ្ឌចម្បងក្នុងការអនុម័តឥណទានទេ។ គ្រឹះស្ថានត្រូវពិនិត្យលក្ខខណ្ឌផ្សេងៗទៀតដែលមានចែងក្នុងគោលនយោបាយរបស់គ្រឹះស្ថានដើម្បីអនុម័តឥណទាន។
- គ្រឹះស្ថានត្រូវរៀបចំឥណទានឡើងវិញជូនអតិថិជន ដោយស្របតាមលក្ខខណ្ឌអនុគ្រោះមួយ ឬច្រើន ដូចមានរៀបរាប់ខាងក្រោមតែប៉ុណ្ណោះ៖

  ១. ការកាត់បន្ថយចំនួនប្រាក់ដើមឥណទាន ឬចំនួនដែលត្រូវទូទាត់សងនៅឥណប្រតិទាន

  ២. ការបន្ថយអត្រាការប្រាក់ទាបជាងលក្ខខណ្ឌនៃកិច្ចសន្យាដើម

  ៣. ការពន្យារពេលទូទាត់សងប្រាក់ដើម ឬការប្រាក់

  ៤. ការពន្យារឥណប្រតិទាន

  ៥. ការបន្ថែម និង/ឬ ការផ្លាស់ប្តូរអ្នករួមខ្ចី

  ៦. ការផ្លាស់ប្តូរពីឥណទានមានការទូទាត់សងតាមការបង់រំលស់ទៅជាការទូទាត់សងតែការប្រាក់ហើយទូទាត់សងប្រាក់ដើមទាំងអស់នៅឥណប្រតិទាន (Bullet Loan) និង/ឬ

  ៧. ការផ្លាស់ប្តូរពីឥណទានមានការទូទាត់សងតែការប្រាក់ហើយទូទាត់សងប្រាក់ដើមទាំងអស់នៅឥណប្រតិទាន (Bullet Loan) ទៅជាការទូទាត់សងតាមការបង់រំលស់។
- គ្រឹះស្ថានត្រូវពិនិត្យ ពិភាក្សា និងជ្រើសរើសលក្ខខណ្ឌអនុគ្រោះមួយ ឬច្រើនខាងលើ ដែលសមស្របបំផុតសម្រាប់អតិថិជន ដើម្បីអាចធានាបានថាអតិថិជនអាចបន្តបំពេញកាតព្វកិច្ចទូទាត់សងបានតាមលក្ខខណ្ឌថ្មីនៃកិច្ចសន្យា។
- គ្រឹះស្ថានត្រូវរៀបចំឥណទានឡើងវិញចំពោះអតិថិជនដែលស្ថានភាពអាជីវកម្ម និង/ឬ ស្ថានភាពហិរញ្ញវត្ថុនៅតែមានចីរភាព ហើយគ្រឹះស្ថានរំពឹងថាអតិថិជនជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ និងការទូទាត់សងតែក្នុងរយៈពេលបណ្តោះអាសន្នប៉ុណ្ណោះ ហើយអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចទូទាត់សងនាថ្ងៃខាងមុខ។

គ្រឹះស្ថានត្រូវមានតម្លាភាពក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងត្រូវពន្យល់អតិថិជនឱ្យបានច្បាស់លាស់អំពីលក្ខខណ្ឌនៃការរៀបចំឥណទានឡើងវិញ ដើម្បីឱ្យអតិថិជនមានមូលដ្ឋានក្នុងការសម្រេចចិត្ត។

គ្រឹះស្ថានត្រូវរាយការណ៍អំពីឥណទានរៀបចំឡើងវិញក្នុងអំឡុងពេលអនុគ្រោះនេះជាប្រចាំខែ តាមទម្រង់របាយការណ៍ ដូចមានក្នុងឧបសម្ព័ន្ធ។ ធនាគារជាតិនៃកម្ពុជា នឹងតាមដានដោយយកចិត្តទុកដាក់ ចំពោះការរៀបចំឥណទានឡើងវិញ និងការដំឡើងចំណាត់ថ្នាក់ឥណទានក្នុងអំឡុងពេលអនុគ្រោះនេះ។

វិធានការអនុគ្រោះចំពោះការរៀបចំឥណទានឡើងវិញខាងលើ មានប្រសិទ្ធភាពអនុវត្តរហូតដល់ ដំណាច់ខែធ្នូ ឆ្នាំ២០២៥។

សារាចរណែនាំនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសាភិបាល**

**ជា សិរី**

**<u>កន្លែងទទួល៖</u>**

- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានត្រួតពិនិត្យ
- អគ្គនាយកដ្ឋានប្រតិបត្តិការ
- អគ្គនាយកដ្ឋានគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ
- អគ្គបេឡា
- អគ្គាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# របាយការណ៍ប្រចាំខែស្តីពី ការរៀបចំឥណទានឡើងវិញ

**MONTHLY REPORT ON RESTRUCTURED LOANS**

កាលបរិច្ឆេទ :

As of:

**ឈ្មោះគ្រឹះស្ថាន:**
**Name of Institution:**

អត្រាប្តូរប្រាក់: Exchange rate: រៀល/ដុល្លារអាមេរិក KHR/USD

(ឯកតាជាលានរៀល)
(In Millions of Riels)

| ល.រ | អតិថិជន | វិស័យ | ឥណទានមុនពេលរៀបចំឡើងវិញ Loans Before Restructuring | | | លក្ខខណ្ឌអនុគ្រោះ | ឥណទានក្រោយពេលរៀបចំឡើងវិញ Loans After Restructuring | | | | ចំណាត់ថ្នាក់ឥណទាន (គិតត្រឹមថ្ងៃរាយការណ៍) តាមបទប្បញ្ញត្តិ | ចំនួនដងនៃការរៀបចំឥណទានឡើងវិញ Number of Restructuring | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ចំនួនឥណទានដុល | ឥណប្រតិទាន | ចំណាត់ថ្នាក់ឥណទានតាមបទប្បញ្ញត្តិ | | ចំនួនឥណទានដុលថ្មី | កាលបរិច្ឆេទនៃឥណទានរៀបចំឡើងវិញ | ឥណប្រតិទាន | ចំណាត់ថ្នាក់ឥណទាន (ក្រោយរៀបចំឥណទានភ្លាម) តាមបទប្បញ្ញត្តិ | | ក្នុងអំឡុងពេលអនុគ្រោះកន្លងមក | ក្នុងអំឡុងពេលអនុគ្រោះនេះ | អនុវត្តតាមបទប្បញ្ញត្តិ (មិនគិតអំឡុងពេលអនុគ្រោះ) |
| No. | Borrowers | Sector | Gross Loan Amounts | Maturity Date | Regulatory Loan Classification | Concession Type | New Gross Loan Amounts | Restructured Date | Maturity Date | Regulatory Loan Classification (right after restructuring) | Regulatory Loan Classification (as of reporting date) | During previous concession periods | During this concession periods | Following regulaton (excluding all concession periods) |
| ១ | | | | | | | | | | | | | | |
| ២ | | | | | | | | | | | | | | |
| ៣ | | | | | | | | | | | | | | |
| ៤ | | | | | | | | | | | | | | |
| ៥ | | | | | | | | | | | | | | |
| ៦ | | | | | | | | | | | | | | |
| ៧ | | | | | | | | | | | | | | |
| ៨ | | | | | | | | | | | | | | |
| ៩ | | | | | | | | | | | | | | |
| ១០ | | | | | | | | | | | | | | |
| សរុប TOTAL: | | | - | | | | - | | | | | | | |

ភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ...........
Reporting Date:

**នាយកធនាគារ**
CEO/Director

**អ្នកត្រួតពិនិត្យ**
Verified by

**អ្នកធ្វើតារាង**
Prepared by